**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការប្រឹក្សាការងារ**

# សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាការងារ

កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ វេលាម៉ោង ៨:៣០ នាទីព្រឹក នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានបើកកិច្ចប្រជុំគណៈកម្មការប្រឹក្សាការងារ អាណត្តិទី៨ លើកទី១១ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍លទ្ធផលកិច្ចប្រជុំក្រុមការងារត្រីភាគីដើម្បីពិភាក្សាអំពីប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៥ ដែលបានបោះឆ្នោតជ្រើសរើសយកតួលេខចំនួន ១១០ ដុល្លារអាមេរិក និងចំនួន ១២១ ដុល្លារអាមេរិក ជូនគណៈកម្មការប្រឹក្សាការងារពិនិត្យ និងពិភាក្សាបន្ត។ ទន្ទឹមនឹងនេះ គណៈកម្មការក៏បានទទួលយកសំណើរបស់ភាគីសហជីពដែលស្នើសុំដាក់តួលេខចំនួន ១៤០ ដុល្លារអាមេរិក សម្រាប់ប្រជុំពិភាក្សាផងដែរ។ ដើម្បីសម្របសម្រួលរវាងភាគីទាំងពីរ ភាគីរាជរដ្ឋាភិបាលបានស្នើដាក់តួលេខចំនួន ១២៣ ដុល្លារអាមេរិក ជូនគណៈកម្មការប្រឹក្សាការងារពិនិត្យសម្រេច។

បើទោះបីជាមានការពិភាក្សាលើតួលេខនីមួយៗក៏ដោយ ក៏កិច្ចប្រជុំមិនបានឈានទៅដល់ការឯកភាពជាឯកច្ឆ័ន្ទលើតួលេខណាមួយឡើយ ដោយភាគីនិយោជកនៅតែរក្សាគោលជំហ ១១០ ដុល្លារអាមេរិក ហើយភាគីសហជីពនៅតែរក្សាគោលជំហ ១៤០ ដុល្លារអាមេរិកដដែល។ ដូច្នេះ កិច្ចប្រជុំបានសម្រេចអនុវត្តនីតិវិធីបន្ត គឺធ្វើការបោះឆ្នោតជាសម្ងាត់លើតួលេខទាំង៣ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

-តួលេខចំនួន ១១០ ដុល្លារអាមេរិក ទទួលបានសំឡេងឆ្នោត ០៧ លើ ២៥។
-តួលេខចំនួន ១២៣ ដុល្លារអាមេរិក ទទួលបានសំឡេងឆ្នោត ១៦ លើ ២៥។
-តួលេខចំនួន ១៤០ ដុល្លារអាមេរិក ទទួលបានសំឡេងឆ្នោត ០២ លើ ២៥។

ដូច្នេះ គណៈកម្មការប្រឹក្សាការងារសូមស្នើតួលេខចំនួន ១២៣ (មួយរយម្ភៃបី) ដុល្លារអាមេរិក ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការពិនិត្យសម្រេចលើប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៥ ស្របទៅតាមបទប្បញ្ញត្តិជាធរមាន នៃច្បាប់ស្តីពីការងារ ដោយត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ តទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤*

| ប្រធានគណៈកម្មការប្រឹក្សាការងារ | អនុប្រធានគណៈកម្មការ ប្រឹក្សាការងារភាគីតំណាងនិយោជក | អនុប្រធានគណៈកម្មការ ប្រឹក្សាការងារភាគីតំណាងកម្មករនិយោជិត |
|---|---|---|
| បណ្ឌិត **អ៊ិត សំហេង** | ឧកញ៉ាបណ្ឌិត **ណាង សុធី** | **ជួន មុំថុល** |

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*